# ដឹងបន្ថែមទៀតអំពីសាលានានា នៃរដ្ឋ Massachusetts!







## ស្វែងរកប័ណ្ណរបាយការណ៍របស់អ្នកនៅ

**reportcards.doe.mass.edu**

## ហេតុការណ៍រហ័សទាំង 5

# អំពីរប័ណ្ណរបាយការណ៍សាលា

1. គ្រាន់តែជាប័ណ្ណរបាយការណ៍របស់សិស្ស បង្ហាញអំពីថាតើពួកគេកំពុងសិក្សាបានយ៉ាងដូចម្តេចលើមុខវិជ្ជាផ្សេងគ្នានានា ប័ណ្ណរបាយការណ៍របស់សាលា គឺការបង្ហាញពីថាតើសាលាឬមណ្ឌលកំពុងប្រព្រឹត្តទៅយ៉ាងដូចម្តេចក្នុងតំបន់ផ្សេងៗគ្នានោះ ។

2. ប័ណ្ណរបាយការណ៍ មានព័ត៌មានជាច្រើននៅក្នុងនោះ គឺ លើសពីអ្វីដែលជាព័ត៌មានស្តីតែពីពិន្ទុនៃ MCAS។

3. ប័ណ្ណរបាយការណ៍សាលា ឆ្លុះបញ្ចាំងពីព័ត៌មានដែលមានតម្លៃបំផុតសម្រាប់គ្រួសារទាំងឡាយនៃរដ្ឋ ម៉ាស្សាជូសិត ។

4. ប័ណ្ណរបាយការណ៍សាលា ចង្អុលបង្ហាញពីកន្លែងដែលសាលាកំពុងធ្វើការល្អ និងត្រង់កន្លែងណាសាលាត្រូវការការកែលម្អឲ្យប្រសើរឡើង ដើម្បី ប្រាកដថាសិស្សទាំងអស់បានជួបនូវអ្វីដែលជាតម្រូវការ ។

5. ថ្នាក់អ្នកដឹកនាំមណ្ឌលទាំងឡាយ និងនាយកសាលាទាំងឡាយ អាចប្រើប័ណ្ណរបាយការណ៍ ដើម្បីគាំទ្រសាលា និងគាំទ្រសិស្សដើម្បីឆ្លុះបញ្ចាំងពីមធ្យោបាយផ្សេងៗដែលជួយដល់សាលាបន្តការកែលម្អឲ្យប្រសើរឡើងទៅមុខទៀតក្នុងរយៈពេលមួយយូរអង្វែង ។

ក្រុមគ្រួសារទាំងឡាយ គឺជាដៃគូដ៏សំខាន់ក្នុងភាពជោគជ័យរបស់សិស្សនៅរដ្ឋ ម៉ាសាជូសេត ។ នាយកដ្ឋានអប់រំបឋមសិក្សានិងមធ្យមសិក្សារដ្ឋ Massachusetts បានប្តេជ្ញាផ្តល់ព័ត៌មានលម្អិតសម្រាប់គ្រួសារទាំងឡាយ ដូច្នេះ ពួកគេមានការយល់ដឹងកាន់តែប្រសើរអំពីការអប់រំរបស់កូនៗរបស់ពួកគេ ។

**សូមចូលទៅកាន់ទំព័រ reportcards.doe.mass.edu ដើម្បីស្វែងរកប័ណ្ណរបាយការណ៍សាលារៀនសម្រាប់រៀងរាល់សាលារដ្ឋនីមួយៗដែលមាននៅក្នុងរដ្ឋនេះ ។**

MASSACHUSETTS DEPARTMENT OF ELEMENTARY AND SECONDARY EDUCATION

# សទ្ទានុក្រមប័ណ្ណរបាយការណ៍

## ព័ត៌មានទូទៅ

*ព័ត៌មានជាគោលមូលដ្ឋានគ្រឹះអំពីសាលារៀន ឬអំពីមណ្ឌល។*

**ស្ថានភាពតាមចំណងជើង I នៃច្បាប់៖** មិនថាសាលារៀន ឬមណ្ឌលទទួលបានមូលនិធិតាមចំណងជើង I នៃច្បាប់ឬអត់។ សាលារៀន និងមណ្ឌលដែលមានប្រជាសិស្សានុសិស្សច្រើនពីក្រុមគ្រួសារដែលមានចំណូលទាបទទួលបានប្រាក់ជំនួយសហព័ន្ធនៃចំណងជើង I នៃច្បាប់ដើម្បីជួយធានាឲ្យបានថាកុមារទាំងអស់បំពេញបានទៅតាមបទដ្ឋានផ្នែកសិក្សាធិការដ៏លំបាករបស់រដ្ឋ ។

## សិស្សានុសិស្ស និងគ្រូបង្រៀន

*ព័ត៌មានអំពីការចុះឈ្មោះរបស់សិស្សានុសិស្ស និងគុណវឌ្ឍិរបស់គ្រូបង្រៀន*

**សិស្សានុសិស្សដែលមានពិការភាព៖** សិស្សានុសិស្សដែលមានតម្រូវការពិសេសដែលមានកម្មវិធីអប់រំតែម្រូវតាមឯកត្តជនម្នាក់ៗ (IEP)។

**ដែលចាញ់ប្រៀបផ្នែកសេដ្ឋកិច្ច៖** សិស្សានុសិស្សដែលទទួលជំនួយតាមរយៈកម្មវិធីជំនួយអាហារូបត្ថម្ភបន្ថែម (SNAP) ជំនួយអន្តរកាលសម្រាប់ក្រុមគ្រួសារដែលមានកូននៅក្នុងបន្ទុក (TAFDC) កម្មវិធីថែទាំការចិញ្ចឹមបីបាច់របស់ក្រសួងកូននិងក្រុមគ្រួសារ (DCF) ឬកម្មវិធី MassHealth។

**តម្រូវការខ្ពស់៖ សិស្សានុសិស្ស**ដែលស្ថិតនៅក្នុងក្រុមមួយ ឬច្រើននៃក្រុមដូចតទៅនេះ៖ សិស្សានុសិស្សដែលមានពិការភាព ជាអ្នកសិក្សាភាសាអង់គ្លេសបច្ចុប្បន្ន ឬពីអតីតកាល និង/ឬ ជាសិស្សានុសិស្សដែលមានការចាញ់ប្រៀបផ្នែកសេដ្ឋកិច្ច។

**សមមូលភាពនឹងការបង្រៀនពេញម៉ោង៖** ចំនួននៃតំណែងបង្រៀនពេញម៉ោងនៅក្នុងសាលារៀន ឬមណ្ឌលសាលារៀន។ តំណែងបង្រៀនខ្លះគឺជាតំណែងមិនពេញម៉ោង ហើយហេតុនេះត្រូវបានរាយការណ៍ថាជាទសភាគ (ឧទាហរណ៍ 0.8)។

## ឱកាសនៃការសិក្សា

*ព័ត៌មានអំពីការចូលរួមរបស់សិស្សនៅក្នុងមុខវិជ្ជាជំទូលំទូលាយ និងពិបាក*

**កិច្ចការក្នុងមុខវិជ្ជាសិក្សាកម្រិតខ្ពស់៖** មុខវិជ្ជាសិក្សាដែលត្រូវបានចាត់ទុកថាកម្រិតខ្ពស់រួមមានការដាក់ចូលរៀននៅក្នុងកម្រិតខ្ពស់ មធ្យមសិក្សាទុតិយភូមិអន្តរជាតិ ការចុះឈ្មោះ សិក្សាថ្នាក់វិទ្យាល័យ និងមហាវិទ្យាល័យ និងថ្នាក់ពិបាកៗដទៃផ្សេងទៀតនៅក្នុងមុខវិជ្ជាសិក្សាផ្សេងៗ។

**MassCore៖** MassCore គឺជាកម្មវិធីដែលណែនាំជាអនុសាសន៍ដោយរដ្ឋនៃការសិក្សាដែលបានរៀបរាប់គ្រួសៗនូវមុខវិជ្ជាស្នូលអប្បបរមាដែលត្រូវការដើម្បីបំពេញបានទៅនឹងការរំពឹងទុកនៃមហាវិទ្យាដែលមានរយៈពេលបួនឆ្នាំ និងកម្លាំងពលកម្ម។ កម្មវិធី MassCore រួមមានបួនមេរៀននៃភាសាអង់គ្លេស បួនមេរៀននៃគណិតវិទ្យា បីមេរៀននៃថ្នាក់វិទ្យាសាស្ត្រដែលមានមូលដ្ឋាននៅក្នុងមន្ទីរពិសោធន៍ បីមេរៀននៃប្រវត្តិវិទ្យា ពីរមេរៀននៃភាសាបរទេសដូចគ្នា មួយមេរៀននៃសិល្បៈ និងមុខវិជ្ជាស្នូលបន្ថែមចំនួនប្រាំមុខវិជ្ជាទៀត។

## វត្តមានសិក្សារបស់សិស្ស និងវិន័យ

*ព័ត៌មានអំពីការមករៀន និងវិន័យរបស់សិស្សានុសិស្ស។*

**ភាពអវត្តមានរ៉ាំរ៉ៃ៖** ភាគរយនៃសិស្សដែលខកខានមិនមករៀន 10 ភាគរយ ឬលើសពីនេះនៃឆ្នាំសិក្សាសាលារៀន (ឧទាហរណ៍ 18 ថ្ងៃឬច្រើនជាងនៅក្នុងឆ្នាំសិក្សាសាលារៀនដែលមានរយៈពេល 180 ថ្ងៃ)។

**វិន័យសិស្សានុសិស្ស៖** ភាគរយនៃសិស្សានុសិស្សដែលត្រូវបានព្យួរមិនឲ្យចូលរៀន បណ្តេញចេញ ឬដកចេញពីសកម្មភាពថ្នាក់រៀនធម្មតាជាលទ្ធផលនៃអាកប្បកិរិយាអវិជ្ជមាន។

## ភាពជោគជ័យក្រោយវិទ្យាល័យ

*ព័ត៌មានអំពីការបញ្ចប់ការសិក្សា ការបោះបង់ចោលការសិក្សា និងអត្រាទៅកាន់មហាវិទ្យាល័យ។*

**លទ្ធផលទទួលបាននៅថ្នាក់វិទ្យាល័យ៖ ព័ត៌មានពីការបញ្ចប់ការសិក្សា** ការបោះបង់ចោលការសិក្សា និងការទៅកាន់មហាវិទ្យាល័យត្រូវបានរាយការណ៍សម្រាប់សាលារៀន និងមណ្ឌលសាលារៀនដែលបម្រើការសម្រាប់ថ្នាក់ទី 9 រហូតដល់ថ្នាក់ទី 12។

## ដំណើរអនុវត្តបានរបស់សិស្សានុសិស្សនៅលើការធ្វើតេស្តថ្នាក់រដ្ឋ

*ព័ត៌មានអំពីដំណើរអនុវត្តបានរបស់សិស្សានុសិស្សនៅលើការធ្វើតេស្តប្រលងរបស់ប្រព័ន្ធវាយតម្លៃប៉ាន់ប្រមាណទូលំទូលាយគ្រប់ជ្រុងជ្រោយរបស់រដ្ឋម៉ាស្សាឈូសេត (MCAS)។ ជារៀងរាល់ឆ្នាំ សិស្សានុសិស្សនៅក្នុងថ្នាក់ទី 3 រហូតដល់ថ្នាក់ទី 8 និងទី 10 ធ្វើតេស្តប្រលង MCAS នៅក្នុងមុខវិជ្ជា ភាសាអង់គ្លេស (ELA) និងគណិតវិទ្យា ហើយសិស្សានុសិស្សនៅក្នុងថ្នាក់ទី 5, 8 និងទី 10 ធ្វើតេស្តប្រលង MCAS ខាងមុខវិជ្ជាវិទ្យាសាស្ត្រ។*

**សមិទ្ធិផលសម្រេចបាន៖** ពិន្ទុ MCAS របស់សិស្សានុសិស្ស។

**ការរីកចម្រើនលូតលាស់របស់សិស្សានុសិស្ស៖ លំដាប់**ភាគរយនៃការលូតលាស់រីកចម្រើនរបស់សិស្សានុសិស្ស (SGP)បង្ហាញថាតើពិន្ទុ MCAS របស់សិស្សានុសិស្សម្នាក់ធៀបទៅនឹងសិស្សានុសិស្សដទៃផ្សេងទៀតដែលមានពិន្ទុ MCAS ស្រដៀងគ្នាពីមុនមកយ៉ាងណា។ SGP របស់សាលារៀន ឬមណ្ឌលសាលារៀនតំណាងឲ្យការលូតលាស់រីកចម្រើនជាមធ្យមសម្រាប់សាលារៀន ឬមណ្ឌលសាលារៀននោះ។

## ការចំណាយ

*ព័ត៌មានអំពីថាតើប្រាក់ប៉ុន្មានដែលត្រូវបានចំណាយក្នុងសិស្សានុសិស្សម្នាក់។*

**លុយដុល្លារដែលចំណាយក្នុងសិស្សានុសិស្សម្នាក់៖ ចំនួនប្រាក់ប្រែប្រួលខុសគ្នាផ្អែកទៅតាម**ការចុះឈ្មោះ ការដាក់បុគ្គលិក ការដំណើរការកម្មវិធីពិសេស និងតម្រូវការរបស់សិស្សនៅក្នុងសាលារៀន។

# សទ្ទានុក្រមប័ណ្ណរបាយការណ៍

**គណនេយ្យភាព**

*ព័ត៌មានអំពីលទ្ធផលគណនេយ្យភាពថ្មីៗបំផុតរបស់សាលារៀន ឬមណ្ឌលសាលារៀន។ ប្រព័ន្ធគណនេយ្យភាពបាននាំផ្តុំចូលគ្នានូវសំណុំនៃរង្វាស់ដើម្បីផ្តល់នូវព័ត៌មានដែលអាចអនុវត្តចេញជាសកម្មភាពបានយ៉ាងច្បាស់អំពីដំណើរអនុវត្តបានរបស់សាលារៀន និងមណ្ឌលសាលារៀនដែលអាចត្រូវបានប្រើប្រាស់ដើម្បីជួយសាលារៀនឲ្យកែលម្អឲ្យប្រសើរឡើង។*

**វឌ្ឍនភាពឆ្ពោះទៅកាន់គោលដៅនៃការកែលម្អ៖** ក្រសួងអប់រំបឋមសិក្សា និងមធ្យមសិក្សានៃរដ្ឋម៉ាស្សាឈូសេត (DESE) កំណត់មុខព្រួញ ឬគោលដៅកែលម្អប្រចាំឆ្នាំសម្រាប់រាល់គ្រប់សាលារៀន និងមណ្ឌលសាលារៀន។ មុខព្រួញត្រូវបានកំណត់សម្រាប់ការសម្រេចបានសមិទ្ធិផល ការលូតលាស់រីកចម្រើន វឌ្ឍនភាពរបស់អ្នកសិក្សាភាសាអង់គ្លេស អវត្តមានរ៉ាំរ៉ៃ ការបញ្ចប់វិទ្យាល័យ និងការបញ្ចប់កិច្ចការក្នុងអំឡុងការសិក្សាកម្រិតខ្ពស់។ សាលារៀន និងមណ្ឌលសាលារៀនត្រូវបានរំពឹងទុកថាបានមានវឌ្ឍនភាពឆ្ពោះទៅកាន់មុខព្រួញទាំងនេះដើម្បីកែលម្អឲ្យបានប្រសើរឡើងនូវដំណើរអនុវត្តបានរបស់សិស្សានុសិស្ស និងរបាយការណ៍ DESE ស្តីអំពីវឌ្ឍនភាពរបស់សាលារៀន និងមណ្ឌលសាលារៀននីមួយៗក្នុងឆ្នាំនីមួយៗ។

**លំដាប់ភាគរយគណនេយ្យភាព៖** លំដាប់ភាគរយគណនេយ្យភាពចង្អុលបញ្ជាក់ថាតើសាលារៀនកំពុងតែមានដំណើរអនុវត្តបានយ៉ាងដូចម្តេចជាសរុបទូទៅធៀបទៅនឹងសាលារៀនដទៃផ្សេងទៀត។ លំដាប់ភាគរយរបស់សាលារៀនត្រូវបានគណនាដោយផ្សំបញ្ចូលព័ត៌មានទាក់ទងនឹងសមិទ្ធិផលសម្រេចបាន ការរីកចម្រើនលូតលាស់ វឌ្ឍនភាពរបស់អ្នកសិក្សាភាសាអង់គ្លេស អវត្តមានរ៉ាំរ៉ៃ ការបញ្ចប់វិទ្យាល័យ និងការបញ្ចប់កិច្ចការក្នុងអំឡុងពេលសិក្សាកម្រិតខ្ពស់។ សាលារៀនដែលមានលំដាប់ភាគរយខ្ពស់ជាទូទៅកំពុងតែមានដំណើរអនុវត្តបានកាន់តែប្រសើរ ហើយសាលារៀនដែលមានលំដាប់ភាគរយកាន់តែទាបជាទូទៅកំពុងតែមានដំណើរអនុវត្តបានកាន់តែអន់។ មណ្ឌលសាលារៀនមិនទទួលលំដាប់ភាគរយគណនេយ្យភាពឡើយ។

**ការចំណាត់ថ្នាក់ជាទូទៅ៖** សាលារៀន និងមណ្ឌលសាលារៀនត្រូវបានដាក់ចូលទៅក្នុងប្រភេទចំនួនពីរ៖ អស់ទាំងឡាយណាដែលត្រូវការជំនួយ ឬអន្តរាគមន៍ពីរដ្ឋ និងអស់ទាំងឡាយណាដែលមិនត្រូវការ។ សាលារៀន និងមណ្ឌលសាលារៀនមួយចំនួនតូចរួមមានអស់ទាំងឡាយណាដែលថ្មី ឬតូចយ៉ាងខ្លាំង ត្រូវបានចាត់ចំណាត់ថ្នាក់ថាមាន "ទិន្នន័យមិនគ្រប់គ្រាន់"។